ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

គណៈកម្មការផ្តល់ភាពស្របច្បាប់ដល់ពលករកម្ពុជា
ដែលកំពុងស្នាក់នៅ និងធ្វើការនៅប្រទេសថៃ
លេខៈ ០២៤/១៧ គ.ផ.ថ/ស.ណ.ន

# សេចក្តីណែនាំ
## ស្តីពីនីតិវិធីនៃការបើកផ្តល់លិខិតឆ្លងដែន/លិខិតធ្វើដំណើរពលករកម្ពុជាធ្វើការនៅបរទេស និងប័ណ្ណពលករកម្ពុជាទៅធ្វើការនៅបរទេស (OCWC)

លេខាធិការដ្ឋានអចិន្ត្រៃយ៍ប្រចាំស្ថានទូតកម្ពុជានៅទីក្រុងបាងកក សូមជម្រាបជូនដល់បងប្អូនពលករកម្ពុជា ក៏ដូចជាសាធារណជនទាំងអស់ជ្រាប អំពីនីតិវិធីក្នុងការបើកផ្តល់លិខិតឆ្លងដែន/លិខិតធ្វើដំណើរ និងប័ណ្ណពលករកម្ពុជាធ្វើការនៅបរទេស (OCWC) ជូនដល់ពលករ និយោជក ឬតំណាងក្រុមហ៊ុន/ និយោជក ដូចខាងក្រោម៖

**១- ឯកសារតម្រូវសម្រាប់ពលករមកទទួលដោយផ្ទាល់**

- ប័ណ្ណមិនមែនសញ្ជាតិថៃ (ប័ណ្ណស៊ីជម្ពូ) ច្បាប់ដើម
- បង្កាន់ទទួលពាក្យសុំផ្តល់លិខិតឆ្លងដែន និងបង្កាន់ដៃទទួលថ្លៃសេវាទ្រទ្រង់ (ករណីបាត់វិក័យបត្រ គឺធ្វើការផ្ទៀងផ្ទាត់មុខរបស់ពលករដោយផ្ទាល់)។
- បុគ្គលដែលមកយកជំនួសត្រូវយកប័ណ្ណមិនមែនសញ្ជាតិថៃ (ប័ណ្ណស៊ីជម្ពូ) ច្បាប់ដើមរបស់ពលករមកបង្ហាញដើម្បីទទួលជំនួសបាន។

**២- ឯកសារតម្រូវសម្រាប់និយោជក មកទទួល**

- លិខិតបញ្ជាក់អត្តសញ្ញាណរបស់និយោជក (អត្តសញ្ញាណប័ណ្ណ, លិខិតឆ្លងដែន, ប័ណ្ណបើកបរ ឬសៀវភៅគ្រួសារ) ច្បាប់ថតចម្លង
- ប័ណ្ណមិនមែនសញ្ជាតិថៃ (ប័ណ្ណស៊ីជម្ពូ) ច្បាប់ថតចម្លងរបស់ពលករម្នាក់ៗ
- បង្កាន់ដៃទទួលពាក្យសុំផ្តល់លិខិតឆ្លងដែន និងបង្កាន់ដៃទទួលថ្លៃសេវាទ្រទ្រង់(ករណីបាត់បង្កាន់ដៃនិយោជក ត្រូវសរសេរបញ្ជាក់ថាបាត់បង្កាន់ទាំង២នេះលើបញ្ជីឈ្មោះប្រគល់-ទទួល (Name List) និងចុះហត្ថលេខាទទួលខុសត្រូវ។

**៣- ឯកសារតម្រូវ សម្រាប់តំណាងនិយោជក ឬក្រុមហ៊ុនមកទទួល**

- លិខិតបញ្ជាក់អត្តសញ្ញាណរបស់និយោជក (អត្តសញ្ញាណប័ណ្ណ, លិខិតឆ្លងដែន ,ប័ណ្ណ បើកបរ, សៀវភៅគ្រួសារ) ច្បាប់ថតចម្លង
- ប័ណ្ណមិនមែនសញ្ជាតិថៃ (ប័ណ្ណស៊ីជម្ពូ) ច្បាប់ថតចម្លងរបស់ពលករម្នាក់ៗ
- លិខិតផ្ទេរសិទ្ធិពីនិយោជកឬក្រុមហ៊ុន និងលិខិតបញ្ជាក់អត្តសញ្ញាណរបស់អ្នកតំណាង (ករណីនិយោជកមិនបានមកដោយផ្ទាល់)



ឃ

- បង្កាន់ដៃទទួលពាក្យសុំផ្តល់លិខិតឆ្លងដែន និងបង្កាន់ដៃទទួលថ្លៃសេវាទ្រទ្រង់ (ករណីបាត់បង្កាន់ដៃ អ្នកតំណាងត្រូវសរសេរបញ្ជាក់ថាបាត់បង្កាន់ដៃលើបញ្ជីឈ្មោះប្រគល់ទទួលរបស់ពលករ (Name List) និងចុះហត្ថលេខាទទួលខុសត្រូវ។

**<u>បញ្ជាក់៖</u>**

**- ក្នុងករណីមិនបើកផ្តល់ ឬមិនចេញវិក័យបត្រ ជូនពលករ/និយោជក ឬអ្នកតំណាងក្រុមហ៊ុន ក្រុមការងារបើកផ្តល់ត្រូវរាយការណ៍ និងបញ្ជាក់មូលហេតុមកលេខាធិការដ្ឋានអចិន្ត្រៃយ៍។**

**- មន្ត្រីនៃគណៈកម្មការផ្តល់ភាពស្របច្បាប់មិនត្រូវបានអនុញ្ញាតឱ្យមកទទួលយកលិខិតឆ្លងដែន/លិខិតធ្វើដំណើរ និងប័ណ្ណពលករកម្ពុជាទៅធ្វើការនៅបរទេសជំនួសពលករ និយោជក និងក្រុមហ៊ុនណាមួយទេ។**

អាស្រ័យដូចបានជម្រាបជូនខាងលើ សូម សាធារណជន ជាពិសេសបងប្អូនពលករកម្ពុជាដែលមកបើកផ្តល់លិខិតឆ្លងដែន/លិខិតធ្វើដំណើរ និងប័ណ្ណពលករកម្ពុជាទៅធ្វើការនៅបរទេស អនុវត្តន៍ទៅតាមគោលការណ៍ខាងលើឱ្យបានខ្ជាប់ខ្ជួន។

រាជធានីភ្នំពេញ ថ្ងៃទី ២២ ខែ សីហា ឆ្នាំ២០១៧

**រដ្ឋមន្ត្រី និងជាប្រធានគណៈកម្មការ**

**អ៊ិត សំហេង**